## តើលោកអ្នកគួរសួរបញ្ជាក់នៅពេលក្រោយទៀត ដោយរបៀបណា?

- **រៀបចំផែនការ។** សូមសរសេរទុកនូវអ្វីៗដែលលោកអ្នក និងគ្រូ នឹងធ្វើដើម្បីជួយដល់កូនរបស់លោកអ្នក។ លោកអ្នកអាចធ្វើអ្វីៗទាំងនេះ ក្នុងពេល ឬក្រោយពេល ប្រជុំ។ សរសេរអ្វីៗដែល លោកអ្នក គ្រូ និងកូន ត្រូវធ្វើ ៗនៅពេលណា និងញឹកញាប់ប៉ុណ្ណា។ រៀបផែនការទៅជួបជាមួយគ្រូ នៅខែក្រោយ។
- **ណាត់ពេលផ្សេងទៀតដើម្បីពិភាក្សាគ្នា។** គួរមានការទាក់ទងគ្នាទៅវិញទៅមក។ សួរគ្រូថា តើលោកអ្នកអាចទាក់ទងទៅគាត់ដោយវិធីណា។ ហើយកុំភ្លេចសួរថាតើគ្រូនឹងទាក់ទងមកលោកអ្នក ដោយវិធីណាដែរ។ មានវិធីទាក់ទងគ្នាជាច្រើន —ជួបគ្នាផ្ទាល់ តាមទូរស័ព្ទ លិខិត អ៊ីមែល។ រៀបចំផែនការដែលងាយស្រួលសម្រាប់អ្នកទាំងពីរ។ ធ្វើយ៉ាងណាឲ្យសាលាមានព័ត៌មានថ្មីៗ សម្រាប់ទាក់ទងមកលោកអ្នក ហើយណាត់ពេលយ៉ាងហោចណាស់ម្តងទៀត ដើម្បីនិយាយជាមួយគ្រូ ក្នុងពីរបីខែក្រោយនេះ។
- **និយាយជាមួយកូន។** ការប្រជុំរវាង មាតាបិតា និងគ្រូ គឺនិយាយតែអំពីកូនរបស់លោកអ្នកតែប៉ុណ្ណោះ ហេតុដូច្នេះហើយ កុំភ្លេចរាប់បញ្ចូលពួកគេ។ ប្រាប់កូននូវអ្វីៗដែលលោកអ្នកបានដឹង ហើយនិយាយពីផែនការសម្រាប់អនុវត្តដែលលោកអ្នក បានរៀបចំជាមួយគ្រូ។ ពន្យល់ពីវិធីដែលលោកអ្នកនឹងជួយកូនឲ្យរៀននៅផ្ទះ ហើយពិភាក្សាគ្នានូវអ្វីៗដែលកូនត្រូវធ្វើ។ សុំយោបល់ពីពួកគេ។

សូមចាំថា ក្មេងម្នាក់ៗ ពិសេស ហើយខុសៗគ្នា។ ក្មេងម្នាក់ៗមាន ចរិតលក្ខណៈប្លែកៗពីគ្នា និងមានចំណូលចិត្តខុសៗគ្នា។ ក្មេងម្នាក់ៗឆ្លើយតបទៅនឹងគ្រឿងជំរុញចិត្តខុសៗគ្នា ហើយអាចរៀនចេះតាមវិធីខុសៗគ្នា។ ក្មេងចាប់ផ្តើមដឹងពីអ្វីៗដែលនៅជុំវិញខ្លួន ហើយមិនអាចសម្រេចចិត្តបានល្អគ្រប់ពេលវេលានោះទេ។ ក្មេង និងយុវវ័យ ម្នាក់ៗអាចមានសមត្ថភាពកែប្រែពិភពលោកបាន តាមការសម្រេចចិត្ត និងការព្យាយាមសម្រេចគោលបំណងរបស់ពួកគេ។ ការគាំទ្រ ការដឹកនាំ និងការលើកទឹកចិត្ត ដល់ពួកគេក្នុងការព្យាយាមឲ្យសម្រេចនូវអ្វីៗដែលពួកគេចង់បាន យើងក៏មានសមត្ថភាពកែប្រែពិភពលោកឲ្យកាន់តែប្រសើរឡើងបានដែរ។ យើងសាមគ្គីគ្នាដើម្បីធ្វើអ្វីៗទាំងនេះ!

*បានយកលំនាំតាម "អង្គប្រជុំរវាង មាតាបិតា និងគ្រូ ទំព័រស្តីពីចំណុចសំខាន់ៗសម្រាប់ នាយកសាលា គ្រូ និងមាតាបិតា - Parent-Teacher Conference Tip Sheets for Principals, Teachers, and Parents" កម្មវិធីស្រាវជ្រាវអំពីក្រុមគ្រួសាររបស់សាកលវិទ្យាល័យ ហាវឺដ (The Harvard Family Research Project) (http://www.hfrp.org/family-involvement/publications-resources/parent-teacher-conference-tip-sheets-for-principals-teachers-andparents) និង "រៀបចំដើម្បីធ្វើឲ្យអង្គប្រជុំរវាង មាតាបិតា និងគ្រូមានជោគជ័យ - Preparing for a Successful Parent-Teacher Conference" ដោយអ្នកស្រី Diane Milne (http://www.education.com/magazine/article/tips-successful-parent-teacher-conference).*


**ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និង ការសហការជាមួយក្រុមសាសនា**

440 N. Broad Street, Room 114, Philadelphia, PA 19130

☎ (២១៥) ៤០០-៤១៨០ | **www.philasd.org/parentuniversity**


# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍ និង ការសហការជាមួយក្រុមសាសនា

PARENT UNIVERSITY

មាតាបិតា គឺជាដៃគូរបស់យើង

THE SCHOOL DISTRICT OF PHILADELPHIA, PA. SCHOOL REFORM COMMISSION

# វិធីធ្វើឲ្យអង្គប្រជុំរវាង មាតាបិតានិងគ្រូ អាចជួយដល់កូនលោកអ្នក

សិស្សានុសិស្សចំណាយពេលធ្វើកិច្ចការនៅសាលាតែ មួយភាគបួននៃពេលវេលារបស់ពួកគេតែប៉ុណ្ណោះ។ ក្នុងកំឡុងពេលនេះ ពួកគេត្រូវតែខំប្រឹងរៀនសូត្រដើម្បីទទួលនូវចំណេះ និងជំនាញ ដែលជាមូលដ្ឋានសម្រាប់ជោគជ័យក្នុងជីវិត នាពេលអនាគត។

អ្នកដែលមានចំណេះដឹងពិតប្រាកដអំពី ការអាន គណិតវិទ្យា ការសរសេរ សង្គមវិទ្យា និងវិទ្យាសាស្ត្រ នឹងមានឱកាសច្រើនជាងគេក្នុងការរក ការងារធ្វើនៅថ្ងៃក្រោយ អាចបានប្រាក់ខែថ្លៃជាង អាចជួយដល់សង្គមឲ្យមានការរីកចម្រើន ហើយអាចធ្វើឲ្យជីវិតរស់នៅមានសុភមង្គល។ ប៉ុន្តែកត្តាផ្សេងៗទៀតជាច្រើន ក៏អាចនាំឲ្យមានជោគជ័យបានដែរ រួមទាំង គុណភាពនៃការឆ្នៃប្រឌិត បញ្ញាវាងវៃនៃការចង់ដឹងចង់ឮ ការចង់ដឹងចង់យល់ ការមិនពឹងពាក់គេ និងការតស៊ូ ព្រមទាំងការប៉ិនប្រសប់ក្នុងការ ធ្វើវិភាគ និងការពិចារណា ការដោះស្រាយបញ្ហា ទំនាក់ទំនង ការរៀបចំ ការចាត់ចែងពេលវេលា និង ការកសាងមិត្តភាព។

ការរួមសហការជាមួយគ្រូរបស់កូនលោកអ្នក នឹងអាចជួយធ្វើឲ្យកូនលោកអ្នក មិនត្រឹមតែមានជោគជ័យក្នុងការសិក្សាតែប៉ុណ្ណោះទេ គឺថែមទាំងជួយក្នុងការធ្វើទំនាក់ទំនងក្នុងសង្គម និង ជួយខាងផ្នែកផ្លូវចិត្ត ទៀតផង។ នៅពេលដែល មាតាបិតា និងគ្រូ រួមសហការគ្នាជារៀងរាល់ថ្ងៃ ដើម្បីគាំទ្រ និងព្យាយាមជួយគ្នាទៅវិញទៅមក ពួកគេអាចកសាងមូលដ្ឋានរឹងមាំសម្រាប់ជោគជ័យរបស់ក្មេង។



ទំព័រដែលមានចំណុចសំខាន់នេះ នឹងជួយលោកអ្នកចាប់ផ្តើមការសន្ទនាជាមួយគ្រូអំពី ការសិក្សារបស់កូន ការសន្ទនាដែលនាំទៅកាន់ការសហការ រវាងលោកអ្នក និងគ្រូ រួមដៃគ្នាដើម្បីជួយកូន។

### តើលោកអ្នកចង់ឃើញអ្វីកើតឡើង?

កម្មវិធីស្រាវជ្រាវអំពីក្រុមគ្រួសាររបស់សាកលវិទ្យាល័យ ហាវឺដ (The Harvard Family Research Project) បានផ្តល់យោបល់ថា ការប្រជុំរវាង មាតាបិតានិងគ្រូ ដែលល្អ គួរបញ្ចូលនូវលក្ខណៈ ដូចតទៅនេះ៖

- **ការសន្ទនាដែលចេះស្តាប់គ្នាទៅវិញទៅមក។**

ដូចជាការសន្ទនាល្អៗទាំងអស់ដែរ ការប្រជុំរវាង មាតាបិតា និងគ្រូ គឺជាការល្អបំផុត បើអ្នកទាំងពីរ និយាយផង ស្តាប់ផង។ ការប្រជុំ

គឺជាពេលដែលលោកអ្នកស្វែងយល់ អំពីការរីកចម្រើនរបស់កូននៅសាលា៖ សុំមើលទិន្នន័យអំពី វត្តមានអវត្តមាន ពិន្ទុ និងពិន្ទុនៃការប្រឡង របស់កូន។ សាកសួរថាតើកូនរបស់លោកអ្នកធ្វើបានតាមការចង់បាន និងកម្រិតនៃការសិក្សា របស់សាលា ឬអត់?

នេះក៏ជាពេលវេលាសម្រាប់គ្រូស្វែងយល់អំពីអ្វីៗដែលកូនលោកអ្នកចូលចិត្តនៅផ្ទះ។ នៅពេលដែលលោកអ្នកជម្រាបគ្រូអំពី ការប៉ិនប្រសប់ ចំណាប់អារម្មណ៍ សេចក្តីត្រូវការ និងការប៉ងប្រាថ្នា របស់កូន គ្រូអាចជួយកូនរបស់លោកអ្នកឲ្យបានកាន់តែច្រើនឡើងថែមទៀត។

### ► ផ្តោតទៅលើការសិក្សា។

ការប្រជុំរវាង មាតាបិតា និងគ្រូ ដែលមានប្រសិទ្ធិភាព គឺផ្តោតទៅលើកម្រិតនៃអ្វីៗដែលកូនធ្វើបានល្អនៅសាលា។ ហើយពួកគេក៏និយាយអំពីវិធីដែលកូនអាចកែលម្អ ដែរ។ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការសន្ទនា សូមមើល កិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ការប្រឡង និងកំណត់សម្គាល់ របស់សាលា មុនពេលប្រជុំ។ ត្រូវកុំភ្លេចយកមកជាមួយនូវបញ្ជីសំណួរដែលលោកអ្នកចង់សួរគ្រូ។

### ► ឱកាសនិងការលំបាកផ្សេងៗ។

គ្រូក៏ចង់ឲ្យកូនរបស់លោកអ្នកមានជោគជ័យ ដូចលោកអ្នកអញ្ចឹងដែរ។ លោកអ្នកនឹងឮយោបល់ល្អៗអំពីការរីកចម្រើនរបស់កូន និងអ្វីៗដែលកូនលោកអ្នកត្រូវកែលម្អ។ ប្រុងប្រៀបទុកជាមុន ដោយគិតអំពីចំណុចពូកែ និងចំណុចខ្សោយ របស់កូនលោកអ្នក។ ត្រៀមខ្លួនជាស្រេចដើម្បីសួរសំណួរអំពីវិធីផ្សេងៗដែលលោកអ្នក និងគ្រូ អាចជួយកូនរបស់លោកអ្នក នូវអ្វីៗដែលពួកគេមានការលំបាក។

## មុនពេលប្រជុំ៖

- ពិនិត្យមើលពេលវេលារបស់លោកអ្នក។ បើសិនជាលោកអ្នកមិនអាចមកសាលា តាមពេលណាត់បាន សួរគ្រូអំពីពេលវេលាផ្សេងទៀតដែលលោកអ្នកអាចមកប្រជុំ។ បើសិនជាមានបញ្ហាក្នុងការមកសាលា ណាត់ពេលប្រជុំគ្នាតាមទូរស័ព្ទ។
- និយាយជាមួយកូនអំពីការរៀនសូត្រ។ អ្វីខ្លះដែលមានដំណើរការល្អ? តើមុខវិជ្ជានិងកិច្ចការអ្វី ដែលកូនចូលចិត្ត និងធ្វើបានល្អ ហើយកិច្ចការអ្វីដែលមានការលំបាក? តើមានអ្វីដែលក្មេងមិនយល់ ឬ មានការលំបាក?
- ពិនិត្យមើល កិច្ចការ ពិន្ទុ និងរបាយការណ៍ពីការរីកចម្រើន របស់កូន។
- និយាយជាមួយអ្នកដ៏ទៃទៀត--សមាជិកគ្រួសារ បុគ្គលិកជំនួយក្រោយម៉ោងសិក្សា អ្នកជួយណែនាំ។ល។ អំពី ចំណុចពូកែ និងសេចក្តីត្រូវការ របស់កូនលោកអ្នក។
- គិតដល់វិធីដែលលោកអ្នកចង់ចូលរួមក្នុងការសិក្សារបស់កូន ដើម្បីលោកអ្នកអាចពិភាក្សាអំពីវិធីទាំងនេះជាមួយគ្រូ។
- សរសេរបញ្ជីសំណួរ ដើម្បីទុកសួរនៅពេលប្រជុំ។

## នេះជាសំណួរខ្លះៗដែលលោកអ្នកអាចសរសេរនៅក្នុងបញ្ជីរបស់លោកអ្នក៖

### ១. មុខវិទ្យា និងកម្រិតទូទៅ នៃការអប់រំ៖

- តើសិស្សានុសិស្សនឹងរៀនមុខវិទ្យាសំខាន់ៗអ្វីខ្លះឆ្នាំនេះ ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងភាសាអង់គ្លេស?
- តើ ចំណេះដឹង និងការប៉ិនប្រសប់ អ្វីដែលគ្រូចង់ឲ្យសិស្ស ចេះចាំឲ្យបានស្ទាត់?
- តើ ចំណេះដឹង និងការប៉ិនប្រសប់ ទាំងនេះត្រូវតាមខ្នាត របស់រដ្ឋ និងប្រទេសរបៀបណា?
- តើមាតាបិតាអាចស្វែងយល់ថែមទៀតអំពី ខ្នាតរបស់រដ្ឋ និងប្រទេស ដោយរបៀបណា?
- តើគេអាចផ្តល់ព័ត៌មានឲ្យសិស្សដឹងអំពីខ្នាតទាំងនេះ ដោយរបៀបណា?

### ២. ការរីកចម្រើន៖

- តើកូនខ្ញុំរៀនបានដូចម្តេចដែរ នៅក្នុងថ្នាក់?
- តើកូនខ្ញុំប្រគល់កិច្ចការរបស់ខ្លួន ដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ទាន់ពេលឬទេ?
- តើកូនខ្ញុំរៀនបានតាមកម្រិតថ្នាក់ឬទេ?
- តើកូនខ្ញុំរៀនបានដូចម្តេច បើប្រៀបធៀបទៅនឹងសិស្សរួមថ្នាក់ឯទៀតៗ?
- តើគ្រូឃើញចំណុចពូកែខាងអ្វី របស់កូនខ្ញុំ?
- តើពួកគេអាចកែលម្អដោយវិធីណា?

### ៣. កិច្ចការដែលគ្រូដាក់ឲ្យធ្វើ និងការវាយតម្លៃ៖

- តើកិច្ចការប្រភេទណា ដែលគ្រូតម្រូវឲ្យសិស្សានុសិស្សធ្វើ?
- តើខ្ញុំអាចមើលកិច្ចការដែលសិស្សបានធ្វើហើយ បានទេ?
- តើគ្រូវាយតម្លៃកិច្ចការដែលដាក់ឲ្យសិស្សធ្វើ ដោយរបៀបណា?
- តើពិន្ទុចុងក្រោយបង្អស់ត្រូវសម្រេចដោយវិធីណា?

### ៤. ការសិក្សានៅផ្ទះ៖

- តើយើងអាចធ្វើអ្វីនៅផ្ទះដើម្បី គាំទ្រ និងជួយបំពេញនូវអ្វីៗដែលសិស្សបានធ្វើនៅក្នុងថ្នាក់រៀន?
- តើយើងអាចដឹងពីកិច្ចការប្រចាំថ្ងៃ ដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ដោយរបៀបណា?
- តើយើងអាចប្រើជំនួយអ្វីថែមទៀត (សៀវភៅ វ៉ិបសៃ ក្លិប)?
- ជម្រាបពីវិធីសាស្ត្រដែលលោកអ្នកបានប្រើ ឬគិតថានឹងប្រើនៅផ្ទះ ដើម្បីគាំទ្រកូនឲ្យមានជោគជ័យក្នុងការសិក្សា។

### ៥. គំនិតរបស់លោកអ្នក អំពីកូន៖

- កុំភ្លេចជម្រាបពី គំនិត និងអារម្មណ៍របស់លោកអ្នក អំពីកូន។
- ជម្រាបគ្រូអំពីអ្វីៗដែលលោកអ្នកគិតថាកូនធ្វើបានល្អ។
- ពន្យល់នូវអ្វីៗដែលកូនត្រូវការជំនួយបន្ថែមទៀត។

### ៦. ជំនួយនៃភាពខុសគ្នាក្នុងការរៀនសូត្រ៖

- តើមានអ្វីកើតឡើងបើសិនជាក្មេងជាសិស្សរៀនយឺត ហើយរៀនមិនទាន់គេ ឬជាសិស្សដែលរៀនលឿន ហើយមានការធុញទ្រាន់? តើគ្រូអាចធ្វើអ្វី ដើម្បីជួយកូនលោកអ្នក នៅពេលដែលពួកគេត្រូវការ?
- តើមានជំនួយអ្វីទៀតនៅសាលា ឬក្នុងសហគមន៍ សម្រាប់សិស្សណាដែលរៀនបានលើសពី ឬមិនបានតាម កម្រិតថ្នាក់?
- តើមានជំនួយសម្រាប់ធ្វើកិច្ចការដែលគ្រូឲ្យយកមកធ្វើនៅផ្ទះ ជួយបង្រៀនបន្ថែម ឬកម្មវិធីផ្សេងៗទៀត សម្រាប់សិស្សានុសិស្សដែលត្រូវការជំនួយបន្ថែម ឬទេ?